Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# ប្រមុខដឹកនាំនៃប្រទេសទន្លេមេគង្គគូសបញ្ជាក់សាជាថ្មីអំពីតួនាទីចម្បង និងពិសេសរបស់គណៈកម្មការទន្លេមេគង្គ ក្នុងការអភិវឌ្ឍតំបន់អាងទន្លេមេគង្គប្រកបដោយចីរភាព

**ខេត្តសៀមរាប ប្រទេសកម្ពុជាថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៨** – ខណៈពេលដែលកិច្ចប្រជុំកំពូល គណៈកម្មការទន្លេមេគង្គលើកទី៣ ត្រូវបានបិទបញ្ចប់នៅថ្ងៃនេះ សេចក្តីប្រកាសសៀមរាប បានទទួលការអនុម័ត ពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ តំណាងដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមបណ្ឌិត ថងលួន ស៊ីសូលីត នាយករដ្ឋមន្ត្រីសាធារណរដ្ឋប្រជាមានិតឡាវ ឯកឧត្តម ឧត្តមសេនីយ ប្រាយុទ្ធ ច័ន្ទអូចា នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និងលោក ង្វៀន សួនហ្វុក នាយករដ្ឋមន្ត្រីសាធារដ្ឋសង្គមនិយមវៀតណាម។

សេចក្តីប្រកាសនេះ បានគូសបញ្ជាក់សាជាថ្មីអំពីការប្តេជ្ញាចិត្តនយោបាយកម្រិតខ្ពស់បំផុតរបស់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ចំពោះកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ ១៩៩៥ និងតួនាទីចម្បងពិសេសរបស់គណៈកម្មការទន្លេមេគង្គ ក្នុងការជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ធនធានទឹក និងធនធានដទៃទៀតប្រកបដោយចីរភាព ក្នុងតំបន់អាងទន្លេមេគង្គ។ កិច្ចប្រជុំកំពូលនេះ ក៏មានការចូលរួមផងដែរពីតំណាងជាន់ខ្ពស់មកពីប្រទេសចិន និងមីយ៉ាម៉ា ដែលជាដៃគូសន្ទនារបស់គណៈកម្មការទន្លេមេង្គ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ នេះ មានប្រសាសន៍ថា "ខ្ញុំសូមគូសបញ្ជាក់សាជាថ្មីអំពីសាមគ្គីភាព និងការប្តេជ្ញាចិត្តរបស់យើង ក៏ដូចជាការគាំទ្រកម្រិតនយោបាយខ្ពស់បំផុតដល់ការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ ប្រកបដោយប្រសិទ្ធភាព"។

សេចក្តីប្រកាសនេះ ផ្តល់ការវាយតម្លៃខ្ពស់ដល់គណៈកម្មការទន្លេមេគង្គ ចំពោះសមិទ្ធផល និងវឌ្ឍនភាព ដែលសម្រេចបានកាលពីពេលថ្មីៗនេះ ចាប់ពីកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ២ មក ដូចជា ការអនុម័ត និងការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍអាងទន្លេ ដោយប្រើប្រាស់គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំផ្សេងទៀតសម្រាប់តំបន់អាទន្លេទាំងមូល ព្រមទាំងការបន្តអនុវត្តនីតិវិធីចំនួន ៥ ដែលផ្តល់លទ្ធភាពឱ្យសមាជិកគណៈកម្មការទន្លេមេគង្គអាចធ្វើការពិគ្រោះយោបល់ និងចរចាជាមួយគ្នាជុំវិញបញ្ហានៃការប្រើប្រាស់ទឹកនៅក្នុងតំបន់អាងទន្លេនេះ។

នាយករដ្ឋមន្ត្រីនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ក៏បានលើកឡើងពីកាលានុវត្តភាព និងបញ្ហាប្រឈម ពាក់ព័ន្ធនឹងការអភិវឌ្ឍផងដែរ។

សេចក្តីប្រកាសនេះ លើកឡើងថា "តំបន់អាងទន្លេមេគង្គផ្តល់នូវឱកាសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការជុំវិញការអភិវឌ្ឍធនធានទឹក នេសាទ ការធ្វើនាវាចរណ៍ ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ទេសចរណ៍ និងបរិស្ថាន រាប់បញ្ចូលទាំងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីផង នៅលើដងទន្លេមេ និងតាមដៃទន្លេ"។

សេចក្តីប្រកាសនេះ ក៏ព្រមានផងដែរថា "បញ្ហាប្រឈមសំខាន់ៗនៅបន្តកើតមាន ដូចជា កំណើនសេដ្ឋកិច្ច និងកំណើនប្រជាជន កំណើនតម្រូវការទឹក ស្បៀង និងថាមពល ការអភិវឌ្ឍ និងការពង្រីកទីក្រុងឧស្សាហាការ/ពាណិជ្ជកម្ម ការបាត់បង់ធនធានបរិស្ថាន តំបន់ដីសើម ធនធាននេសាទធម្មជាតិ ការបាត់បង់ព្រៃឈើ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត និងហានិភ័យដល់ជីវចម្រុះ ព្រមទាំងជីវភាពរស់នៅ និងទ្រព្យសម្បត្តិនានារបស់ប្រជាពលរដ្ឋ"។

សេចក្តប្រកាសនេះបានបន្តលើកឡើងថា ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ រំពឹងថាគណៈកម្មការនេះនឹងខិតខំលើកកម្ពស់កិច្ចខិតខំប្រឹងប្រែង និងភាពជាដៃគូរួមគ្នាដើម្បីផ្តល់នូវឱកាសអភិវឌ្ឍឱ្យបានល្អបំផុត និងឆ្លើយតបចំពោះបញ្ហាប្រឈម និងហានិភ័យនានា តាមរយៈការអនុវត្តដំណើរការពហុវិស័យដែលមានលក្ខណៈចម្រុះ បរិយាប័ន្ន គិតគូពីយេនឌ័រសម្រាប់តំបន់អាងទន្លេទាំងមូល។ ការលើកឡើងនេះ គឺស្របជាមួយនឹងសារគន្លឹះសំខាន់ៗដែលចេញពីសន្និសីទអន្តរជាតិរយៈពេល ២ ថ្ងៃ រៀបចំមុនកិច្ចប្រជុំកំពូលនេះ ដែលមានអ្នកចូលរួមប្រមាណ ៤០០ នាក់។

នាយកប្រតិបត្តិលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ លោក ផាំ ទាន់ហ្វិន បានមានប្រសាសន៍ថា "នៅក្នុងកិច្ចប្រជុំកំពូលនេះ មានការបញ្ជាក់យ៉ាងច្បាស់ថា គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាលដ៏សំខាន់ ដែលមានតួនាទីដឹកនាំការអភិវឌ្ឍតំបន់អាងទន្លេមេគង្គប្រកបដោយចីរភាព។ ការពិភាក្សានៅសប្តាហ៍នេះ បានបញ្ជាក់យ៉ាងច្បាស់ថា គណៈកម្មការទន្លេមេគង្គ ដែលជាមជ្ឈមណ្ឌល និងវេទិកាប្រមូលផ្តុំចំណេះដឹងដែលមានវ័យចំណាស់មួយនេះ អាចបន្តជំរុញឱ្យមានការសម្របសម្រួល ដើម្បីឱ្យមានការអនុវត្តកិច្ចខិតខំប្រឹងប្រែងសហការរួមគ្នាបន្ថែមទៀតពីសំណាក់បណ្តាប្រទេសនានា សំដៅឆ្លើយតបចំពោះបញ្ហាប្រឈមនានាដែលកំពុងកើតមាននាពេលនេះ ដោយត្រូវធ្វើការពិចារណាពីលទ្ធផលរកឃើញចេញពីការសិក្សារបស់ក្រុមប្រឹក្សា (ហៅកាត់ថា Council Study)"។

ឯកឧត្តម អ៊ី ជឹងពីង រដ្ឋមន្ត្រីធនធានទឹកចិន មានប្រសាសន៍ថា ប្រទេសចិនស្វាគមន៍ការបំពេញតួនាទី ក្នុងលក្ខណៈស្ថាបនា របស់គណៈកម្មការទន្លេមេគង្គ និងលេខាធិការដ្ឋានរបស់គណៈកម្មការនេះ ក្នុងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។ ឯកឧត្តម អ៊ុង វីន រដ្ឋមន្ត្រីក្រសួងអភិរក្សធនធានធម្មជាតិ និងបរិស្ថានរបស់ប្រទេសមីយ៉ាន់ម៉ា ក៏បានចូលរួមសម្តែងការស្វាគមន៍នេះផងដែរ និងបានបង្ហាញពីការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មការទន្លេមេគង្គ។

តំណាងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលនេះ ក៏បានលើកឡើងផងដែរថា គណៈកម្មការទន្លេមេគង្គ បានឆ្លងកាត់នូវការផ្លាស់ប្តូរ និងបានសម្រេចជោគជ័យយ៉ាងច្រើន ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។

ការប្រារព្ធខួបអបអរសាទរកិច្ចព្រមព្រៀងមេគង្គដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃ ៥ ខែ មេសា ឆ្នាំ ១៩៩៥ ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ អមជាមួយនឹងការអបអរសាទរទិវាទន្លេមេគង្គ។ ឆ្នាំនេះ ការប្រារព្ធអបអរ

សាទរខួបកិច្ចព្រមព្រៀងទន្លេមេគង្គត្រូវបានធ្វើឡើងតាមរយៈការដាក់តាំងបង្ហាញពីសមិទ្ធផល និងផលិតផលសំខាន់ៗរបស់គណៈកម្មការទន្លេមេគង្គ ដូចជា អត្ថបទដែលឈ្នះជ័យលាភីការប្រកួតប្រជែងសំណេរដែលរៀបចំធ្វើឡើងកាលពីពេលថ្មីៗនេះ អំពីទន្លេមេគង្គ នៅក្នុងកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គលើកទី ៣ និងសន្និសីទអន្តរជាតិ។

អាទិភាពជទៃទៀត ដែលត្រូវបានបញ្ចូលនៅក្នុងសេចក្តីប្រកាសនោះផងដែរ រួមមាន ការបន្តរក្សាសមិទ្ធផល ដែលសម្រេចបានកាលពីពេលថ្មីៗនេះ ក្នុងការអនុវត្តនីតិវិធីស្តីពីការប្រើប្រាស់ទឹកនៅក្នុងតំបន់អាងទន្លេ ការអនុវត្តយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់តំបន់អាងទន្លេទាំងមូល ជាពិសេស ការអនុវត្តគម្រោងរួមគ្នា ការពង្រឹងបណ្តាញពិនិត្យតាមដានអាងទន្លេទាំងមូលរបស់គណៈកម្មការទន្លេមេគង្គ និងប្រព័ន្ធព្យាករណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មាន ដែលមានសារៈសំខាន់សម្រាប់បណ្តាញពិនិត្យតាមដាន និងប្រព័ន្ធព្យាករណ៍ ការកំណត់ និងការអនុវត្តឱកាសសម្រាប់បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូនានា និងក្របខ័ណ្ឌសហប្រតិបត្តិការថ្នាក់តំបន់សំខាន់ៗ ដូចជា សហប្រតិបត្តិការមេគង្គ-ឡានឆាង ជាដើម។

ចុងក្រោយ ប្រមុខរាជរដ្ឋាភិបាលបានគូសបញ្ជាក់សាជាថ្មីពីការគាំទ្ររបស់ពួកគេ ចំពោះការបន្តកែទម្រង់ស្ថាប័នរបស់គណៈកម្មការទន្លេមេគង្គ ដែលកំពុងអនុវត្តយ៉ាងល្អប្រសើរដើម្បីប្រែក្លាយគណៈកម្មការនេះឱ្យទៅជាស្ថាប័នដែលតូចជាងមុន មានប្រសិទ្ធភាព និងអាចរក្សាចីរភាពហិរញ្ញវត្ថុដោយខ្លួនឯងបាន។

កិច្ចប្រជុំកំពូលបន្ទាប់របស់គណៈកម្មការទន្លេមេគង្គ នឹងធ្វើឡើង ៤ ឆ្នាំទៀត ក្នុងខែ មេសា ឆ្នាំ ២០២២ ក្នុងប្រទេសឡាវ។

**កំណត់សម្គាល់ចំពោះនិពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាលដែលមានតួនាទីជំរុញ លើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងអាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គរវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះបំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់កាទូតផ្នែកទឹក ក៏ដូចជាមជ្ឈមណ្ឌលចំណេះដឹងស្តីពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពរបស់តំបន់នេះ។

**- ចប់ -**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភក្ត្រ
មន្ត្រីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល: sopheak@mrcmekong.org
ទូរសព្ទ: +855-12266653/856-20-77779168